# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ តាមប្រវត្តិសាស្ត្រ ព្រះបាទជ័យវរ្ម័នទី៧មានបន្ទូលថា «សេចក្តីទុក្ខរបស់ប្រជារាស្ត្រ ជាសេចក្តីទុក្ខរបស់ព្រះអង្គ» ប្រៀបមកព្រះពុទ្ធជាម្ចាស់ ។

www.hoksavann.org

ថ្ងៃទី២១ មិថុនា ២០១១



ពាក្យរបស់ព្រះបាទជ័យវរ្ម័នទី៧ថា «សេចក្តីទុក្ខរបស់ប្រជារាស្ត្រ ជាសេចក្តីទុក្ខរបស់ព្រះអង្គ»នេះ ពោលក្នុងសម័យដែលប្រទេសកម្ពុជាចំរើនរុងរឿង ជាមហាអំណាចនៅទ្វីបអាស៊ី ។ ពាក្យនេះមានន័យថា ព្រះអង្គរួមសុខរួមទុក្ខជាមួយប្រជារាស្ត្រ ក្នុងនាទីព្រះអង្គជាអ្នកទទួលខុសត្រូវលើវាសនាជាតិ ។ បានសេចក្តីទៀតថា សេចក្តីទុក្ខរបស់ប្រជារាស្ត្រ ដូចជាទុក្ខរបស់ព្រះអង្គ ។ បើព្រះអង្គមានព្រះទ័យដូច្នេះ ពេលដែលប្រជារាស្ត្រមានទុក្ខ ព្រះអង្គពុំព្រងើយកន្តើយឡើយ តែងតែរកវិធីដោះស្រាយឲ្យរួចពីទុក្ខនោះ ។ ឧទាហរណ៍បើប្រជារាស្ត្រក្រីក្រលំបាកក្នុងការចិញ្ចឹមជីវិត ព្រះអង្គចាត់វិធានការគ្រប់បែបយ៉ាង ដើម្បីលើកដំកើងជីវភាពប្រជារាស្ត្រ ។ ជាភស្តុតាង គេឃើញបារាយណ៍ទឹកថ្លា ដែលត្រូវបានជីកឡើងសម័យនោះ ជាការបញ្ជាក់ថា ព្រះអង្គលើកដំកើងកសិកម្ម ដែលប្រជារាស្ត្រខ្មែរភាគច្រើនជាកសិករ ឲ្យមានទឹកបរិបូណ៌ធ្វើស្រែចំការ ។ ក្រៅពីសង្គមកិច្ច ផ្នែកវប្បធម៌ក៏ចំរើនលូតលាស់ខ្លាំងណាស់ដែរ ជាភស្តុតាង ព្រះនាងឥន្ទ្រទេវី ជាអគ្គមហេសីរបស់ព្រះអង្គ ជាសាកលវិទ្យាធិការិនី ។ បញ្ជាក់ថា សម័យនោះការសិក្សាឆមានរហូតដល់សាកលវិទ្យាល័យ ។ អរិយធម៌ខ្មែរចំរើនខ្ពង់ខ្ពស់ណាស់សម័យនោះ ហើយបានជះឥទ្ធិពលទៅលើប្រទេសជិតខាងផង ។ ដីគោកនិងសមុទ្រធំទូលំទូលាយណាស់ ។ ផ្នែកការបង្រួបបង្រួមជាតិ ដោយព្រះអង្គគោរពព្រះពុទ្ធសាសនាយ៉ាងមុតមាំ ព្រះអង្គបានយកធម៌ព្រហ្មវិហារ មានមេត្តា ករុណាជាដើម ជាទឹកបន្សាផ្សារភ្ជាប់ប្រជារាស្ត្រឲ្យសាមគ្គីជុំវិញព្រះអង្គ ។ ជាភស្តុតាងគេរកឃើញរូបព្រះកេសរបស់ព្រះអង្គធ្វើពីថ្មមានព្រះភ័ក្ត្រញញឹមយ៉ាងជ្រៅប្រកបដោយគតិបណ្ឌិត្យ និងប្រកបដោយព្រហ្មវិហារធម៌ឥតព្រំដែន ។ ការវិវាទផ្ទៃក្នុងនិងការឈ្លានពានពីបរទេស ពុំឃើញកើតមាន ដែលគួរឲ្យកត់សំគាល់ឡើយក្នុងសម័យព្រះអង្គ ។ គេសន្និដ្ឋានថា របបគ្រប់គ្រងរបស់ព្រះអង្គមានអ្នកចេះដឹងច្រើនណាស់ ជាពិសេសអ្នកចេះដឹងធ្វើជាទីប្រឹក្សា ។ មានច្បាប់ក្បួនចំបាំងនិងច្បាប់ក្បួនសំរាប់គ្រប់គ្រងប្រទេស ដែលប្រទេសជិតខាងចង់បានយកទៅអភិវឌ្ឍន៍នៅប្រទេសគេ ហើយសម័យក្រោយមកកើតរឿងព្រះគោព្រះកែវ គឺព្រះគោតំណាងក្បួនច្បាប់ខ្មែរ ឯព្រះកែវតំណាងអ្នកប្រាជ្ញខ្មែរដែលថៃប្រមូលយកទៅ ។

ចំណែកព្រះពុទ្ធជាម្ចាស់ ក៏ព្រះអង្គរួមសុខរួមទុក្ខជាមួយនឹងមនុស្សជាតិទូទៅ ។ បេសកកម្មរបស់ព្រះអង្គក្នុងការកសាងឲ្យបានត្រាស់ដឹងជាព្រះពុទ្ធនេះ គឺយកធម៌ត្រាស់ដឹងនេះទៅប្រោសមនុស្សសត្វឲ្យរួចចាកទុក្ខ ។ សេចក្តីទុក្ខរបស់មនុស្សសត្វ គឺការកើតចាស់ឈឺស្លាប់ ។ ការកសាងបារមីធម៌ឲ្យបានត្រាស់ជាព្រះពុទ្ធមានរយៈវេលាដ៏យូរជាច្រើនជាតិ ទទួលទុក្ខលំបាកដ៏ខ្លាំងក្លា ក៏ដើម្បីជួយរំដោះទុក្ខមនុស្សសត្វ ។ បើកសាងត្រឹមតែបានសំរេចជាព្រះបច្ចេកពុទ្ធ ឬជាព្រះអរហន្តរំដោះទុក្ខតែព្រះអង្គឯង ពុំមែនបំណងប្រោសសត្វ ត្រូវកសាងមានរយៈពេលខ្លី ។ បើព្រះអង្គត្រាស់ដឹងហើយ បរិនិញ្វានទៅមិនបាច់ប្រោសសត្វក៏បាន តែខុសពីបំណងរបស់ព្រះអង្គ គឺត្រាស់ដឹងដើម្បីប្រោសសត្វ ។ ដូច្នេះបញ្ជាក់ថា ព្រះពុទ្ធពិតជារួមសុខរួមទុក្ខជាមួយមនុស្សសត្វ សេចក្តីទុក្ខរបស់មនុស្សសត្វ ជាសេចក្តីទុក្ខរបស់ព្រះអង្គ បានជាព្រះអង្គសំដែងធម៌ប្រោសមនុស្សសត្វដោយបង្ហាញមាគ៌ារំដោះទុក្ខចប់សព្វគ្រប់ហើយ ទើបព្រះអង្គបរិនិញ្វាន ។ ព្រះពុទ្ធសមណគោតមបានសំដែងធម៌ទេសនាប្រោសសត្វអស់រយៈវេលា៤៥ឆ្នាំ ហើយពាក្យប្រៀនប្រដៅរបស់ព្រះអង្គត្រូវបានសរសេរទុកក្នុងគម្ពីរព្រះត្រៃបិដក ទុកឲ្យមនុស្សសត្វសិក្សានិងប្រតិបត្តិតាមតទៅទៀត ។

អ្នកដឹកនាំខ្មែរនៃប្រទេសកម្ពុជា គួរពិនិត្យពិចារណាមើលការដឹកនាំរបស់ព្រះបាទជ័យវរ្ម័នទី៧ ដែលធ្វើឲ្យប្រទេសកម្ពុជាចំរើនលូតលាស់និងមានសន្តិភាព មានឯកភាពជាតិ ។ សម័យនោះ ទោះបីរបបប្រជាធិបតេយ្យពុំទាន់កើតមានពេញលក្ខណៈក៏ដោយ ក៏ព្រះអង្គគ្រប់គ្រងប្រទេសប្រកបដោយធម៌ព្រះពុទ្ធសាសនា ដែលជាមាគ៌ាដ៏ល្អឥតខ្ចោះ ដូចជាគោរពទសពិធរាជធម៌១០យ៉ាងរបស់អ្នកដឹកនាំជាដើម ។ អ្នកដឹកនាំខ្មែរត្រូវតែគោរពតួនាទីរបស់ខ្លួនជាអ្នកបំរើរាស្ត្រ ពុំមែនធ្វើឲ្យប្រជារាស្ត្រក្រ ដូចជាកេងប្រវ័ញ្ចយកដីរាស្ត្រដោយឲ្យតម្លៃយ៉ាងទាបបំផុត ។ ប៉ូលិសកងរាជអាវុធហត្ថបង្កើតឡើង សំរាប់ការពារសន្តិសុខជូនរាស្ត្រ ពុំមែនបង្កើតសំរាប់បង្ក្រាបបាតុកម្ម វាយប្រជារាស្ត្រដោយដំបងឆក់ រហូតបាញ់សម្លាប់ប្រជារាស្ត្រឡើយ ។ តុលាការស៊ីប្រាក់ខែពីរាស្ត្ររកយុត្តិធម៌ជូនរាស្ត្រ ពុំមែនបង្កើតឡើងសំរាប់បំរើអ្នកមានអំណាចឡើយ ។ ត្រូវចាត់ទុកសេចក្តីទុក្ខរបស់រាស្ត្រជាសេចក្តីទុក្ខរបស់ខ្លួន ដូចពាក្យព្រះបាទជ័យវរ្ម័នទី៧ ។៚

* *

*